ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភារដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៦៣

ចុះថ្ងៃទី០៤ខែមិថុនាឆ្នាំ១៩៩៨

សាលដីកា

លេខ : ១០៤

ចុះថ្ងៃទី២៨ខែមិថុនាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ១៩៩៩

ដោយមានសមាសភាពដូចតទៅ

១- ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២- លោក ប៉ែន ស៊ិន ជាចៅក្រម

៣- លោក ទេ វ៉ុល មួន ជាចៅក្រម

៤- លោក ជីវ កេង ជាចៅក្រមរបាយការណ៍

៥- លោក ស៊ិន ងឹម ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា សេន សុខា

តំណាងមហាអយ្យការ

លោក ដួន ស៊ុនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ១០១ ចុះថ្ងៃទី ១៦ ខែ មិនា - ឆ្នាំ ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥៣៧ ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ទេព ណាត អាយុ៦០ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិក - ពេទ្យចូលនិវត្តន៍ ទីលំនៅភូមិ២០ឧសភា ឃុំស្វាយទៀប ស្រុកស្វាយទៀប ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ទេព ឡាត "ស" ម្តាយឈ្មោះ ផេត អ៊ី "ស" ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ដូ គឹមរិន អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរ - បុគ្គលិកមន្ទីរសាធារណការ ទីលំនៅភូមិ២០ឧសភា ក្រុម៤ ឃុំស្វាយទៀប ស្រុកស្វាយទៀប ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ដូ ចាវ "ស" ម្តាយឈ្មោះ កង ណាយ "ស" ។

មានមេធាវី លោក ប៊ូ សាវុន

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារផ្ទះ

តាមបណ្តឹងសាទុក្ខលេខ ៦៣ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៨ របស់អ្នកស្រីលី ណារី បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ១០១ ចុះថ្ងៃទី ១៦ ខែមិនា ឆ្នាំ ១៩៩៨ លើចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៦៣ ចុះថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ ១៩៩៨របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ០២.៧.៩០ ឈ្មោះ ជូ គឹមរិន ប្ដឹងសុំសិទ្ធិគ្រប់គ្រងផ្ទះលេខ៤៩.១៥ ស្ថិតនៅផ្លូវលេខមួយកន្លះក្រុម១១ ភូមិ២០ឧសភា ឃុំស្វាយចៅ ខេត្តបាត់ដំបង ពីឈ្មោះទេព ណាត ដោយសំអាងថា ខ្លួនបានទិញផ្ទះពីចុងចម្លើយតាំងពីខែសីហា ឆ្នាំ១៩៨៦ តំលៃ២ជី ៥ហ៊ុន ។

បានឃើញសាលក្រមលេខ ១៧៧ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៧ របស់តុលាការខេត្តបាត់ដំបងដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១.ក. ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ០២.០៧.១៩៩០ របស់ឈ្មោះ ជូ គឹមរិន ជាដើមចោទប្ដឹងសុំសិទ្ធិគ្រប់គ្រងផ្ទះជាន់ក្រោមលេខ អ៊ី០ ៤៩.១៥ ស្ថិតនៅផ្លូវលេខមួយកន្លះ ភូមិ២០ឧសភា ឃុំស្វាយចៅ ស្រុកស្វាយចៅ ខេត្តបាត់ដំបង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

ខ. ទទួលយកសំណូមពរនាពេលសវនាការរបស់ដើមចោទឈ្មោះ ជូ គឹមរិន សុំអោយចុងចម្លើយរួមទាំងកូនឈ្មោះ លី ណារី រុះរើសំភារៈ និង ចុះចេញពីផ្ទះដោយឧបត្ថម្ភថ្លៃរុះរើទុកជាត្រឹមត្រូវតាមគតិច្បាប់ ។

២_ ក. ចាត់បញ្ចូលឈ្មោះ លី ណារី ជាតតិយជនចុងចម្លើយ ក្នុងរឿងក្ដីលេខ ១៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩១ ។

ខ. បដិសេធចោលសំណូមពររបស់ចុងចម្លើយឈ្មោះ ទេព ណាត នាពេលស៊ើបអង្កេតដោយសុំគ្រប់គ្រងផ្ទះ អ៊ី០ លេខ៤៩.១៥ ជាកម្មសិទ្ធិដោយផ្ទុយនឹងគតិច្បាប់ ។

៣_ បដិសេធប័ណ្ណសំគាល់កម្មសិទ្ធិលេខ ១០០៦ ចុះថ្ងៃទី ២៣.៧.១៩៩១ របស់គណៈកម្មាធិការប្រជាជនខេត្តបាត់ដំបង អោយដល់ឈ្មោះ នាង លី ណារី ផ្ទះលេខអ៊ី០ លេខ ៤៩.១៥ នៅភូមិ២០ឧសភា ឃុំស្វាយចៅ ស្រុកស្វាយចៅ ខេត្តបាត់ដំបង ចោលជាអសារបង់ ។

៤_ ប្រគល់ជាកម្មសិទ្ធិអោយដល់ដើមចោទឈ្មោះ ជូ គឹមរិន និង ប្រពន្ធឈ្មោះរី គឹមសាននូវផ្ទះលេខ ៤៩.១៥ នៅផ្លូវលេខមួយកន្លះ ភូមិ២០ឧសភា ឃុំស្វាយចៅ ស្រុកស្វាយចៅ ខេត្ត_បាត់ដំបង គិតចាប់តាំងពីថ្ងៃដែលសាលក្រម់នេះចូលជាស្ថាពរ ។

៥_ អោយឈ្មោះ នាង ទេព ណាត ជាចុងចម្លើយ និង ឈ្មោះ នាង លី ណារី ជាតតិយជនចុងចម្លើយរុះរើសំភារៈបរិក្ខាដែលជាកម្មសិទ្ធិផ្ទាល់ចេញពីផ្ទះ អ៊ី០ លេខ ៤៩.១៥ ផ្លូវលេខមួយកន្លះ ភូមិ២០ឧសភា ឃុំស្វាយចៅ ស្រុកស្វាយចៅ ខេត្តបាត់ដំបង ក្នុងរយៈពេលពីរខែក្រោយពេលសាលក្រមចូលជាស្ថាពរ ។ តែអោយឈ្មោះ ជូ គឹមរិន ជាដើមចោទចេញសោហ៊ុយរុះរើចំនួន ៣០០.០០០រៀល "សាមសិបម៉ឺនរៀល" អោយដល់ឈ្មោះ ទេព ណាត និង នាង លី ណារី ។

៦_ ទុកសិទ្ធិអោយដល់អ្នករស់នៅជាន់ទី១គឺ អ៊ី១ ផ្ទះលេខ ៤៩.១៥ មានសិទ្ធិចុះឡើងចេញចូលដើរឆ្លងកាត់តាមផ្ទះ អ៊ី០ ផ្ទះលេខ ៤៩.១៥ តាមការកំណត់របស់កម្មសិទ្ធិករ ។

តាមអនុក្រឹត្យលេខ ២៥អនក្រ ចុះថ្ងៃទី ២២.៤.១៩៨៩ តាមសេចក្ដីណែនាំលេខ៧៣ ចុះថ្ងៃទី ២៧.៧.១៩៩៥ ទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

---៣---

៧

៧_ អោយចុងចម្លើយឈ្មោះ ទេព ណាត បង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រៀល គឺ : ពន្ធចុះបញ្ជីក្តី និង ពន្ធផ្ទឹងចំនួន ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០រៀល ចំណាយក្នុងកិច្ចស៊ើបសួរ និង អ្នកប្រគល់ដីកាកោះចំនួន ៥.០០០រៀល សរុប ៧.០០០រៀល ប្រាក់នេះត្រូវកាត់យកពីប្រាក់ ៧.០០០រៀល ដែលដើមចោទបានបង់រួចហើយ បើបួសឧទ្ធរណ៍អោយចុងចម្លើយសងប្រាក់ ៧.០០០រៀល ទៅដើមចោទវិញ និង អោយបង់ពន្ធសមាមាត្របន្ថែមទៀត $\frac{\text{១ គុណ ៥.០០០.០០០}}{\text{១០០}}$ ស្មើ ៥០.០០០រៀល កាលបើសាលក្រមនេះចូលជាស្ថាពរ ។ ប្រាក់នេះត្រូវដាក់ចូលក្នុងថវិការរដ្ឋចំនួន ៨០ភាគរយ និង ២០ភាគរយ សំរាប់រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី ០៨.០២.១៩៩៣ ។

៨_ សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទឈ្មោះ ជូ គឹមរិន និង ភរិយាឈ្មោះ លី ណារី កំបាំងមុខចុងចម្លើយ ។ ទុករយៈពេលប្តឹងទាស់ និង បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៦២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៧ របស់អ្នកស្រី លី ណារី ជាភរិយាជន ដែលប្តឹងជំទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ ១៧៧ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៧ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចទាំងស្រុងនៃសាលក្រម ។

បានឃើញសាលដីកាលេខ ១០១ ចុះថ្ងៃទី ១៦ ខែមិនា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៥.៧.៩៧ របស់ឈ្មោះ លី ណារី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២_ តម្កល់សាលក្រមលេខ ១៧៧ ចុះថ្ងៃទី ១១.៧.៩៧ របស់តុលាការខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣_ កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធផ្ទឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើដីកាកោះ ៥.០០០៛ និង អាជ្ញាធរតុលាការ ៥.០០០៛ ។

៤_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៦៣ ចុះថ្ងៃទី ២៥ ខែមិនា ឆ្នាំ ១៩៩៨ របស់អ្នកស្រី លី ណារី ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃគ្រប់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៨ របស់អ្នកស្រី លី ណារី ។

បានឃើញសារណាតបចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់លោក ជូ គឹមរិន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដំបូងលេខ១០១ ចុះថ្ងៃទី ១៦ ខែ មិនា ឆ្នាំ ១៩៨៨ របស់សាលាឧទ្ធរណ៍ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណានិងសំរេចអំពីសិទ្ធិរបស់អ្នកស្រី លី ណារី លើផ្ទះទំនាស់នេះ ដែលជាមធ្យោបាយដ៏សំខាន់ក្នុងការពិនិត្យ និង សំរេចសុពលភាពនៃការលក់ទិញផ្ទះទំនាស់រវាងអ្នកស្រី ទេព ណាត និង លោក ជូ គឹមរិន ដើម្បីកុំអោយមានការបំពានលើមាត្រា ៣៥ នៃក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ចុះថ្ងៃទី ២៨.១០.៨៨ ។

- អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

ក្រឡាបញ្ជីឡើងអានសារណារបស់ឈ្មោះ ទេព ណាត ។

ក្រឡាបញ្ជីឡើងអានសារណាតបរបស់ឈ្មោះ ជូ គឹមរិន ។

លោក មេធាវី ប៊ូ សារ៉ុន បានធ្វើសេចក្តីសន្និដ្ឋានការពារអោយចុងបណ្តឹងសាទុក្ខ និង ជាចុងចម្លើយ នៅពេលសវនាការថា : ខ្លួនសុំអោយក្រុមប្រឹក្សាពិចារណាលើសារណារបស់កូនក្តីខ្លួនផងហើយខ្លួនសុំលើកឡើងនៅចំណុចខ្លះដូចតទៅ ។

- លី ណារី បានបំភ័ន្តថា ម្តាយខ្លួនបានប្រគល់ផ្ទះនេះអោយខ្លួនតាំងពីឆ្នាំ ១៩៨១ នោះគឺជាការបំភ័ន្តព្រោះ លី ណារី ជាសមាជិកគ្រួសារដែលមានប្តីឈ្មោះ ទេព ណាត ជាមេគ្រួសារ ។

- ការបំបែកគ្រួសាររបស់ លី ណារី ទើបតែធ្វើឡើងនៅពួកគេចាញ់ក្តីនៅសាលាឧទ្ធរណ៍ ហើយឈ្មោះ ទេព ណាត គាត់នៅរស់នៅខេត្តកំពង់ស្ពឺ ។

- មានភស្តុតាង និង សាក្សីគ្រប់គ្រាន់បញ្ជាក់ថា ផ្ទះនេះពិតជាផ្ទះរបស់កូនក្តីខ្លួនមែន ។ បើយោងទៅតាមសំអាងហេតុ និង សាលក្រមរបស់តុលាការខេត្តបាត់ដំបង និង សាលដីការបស់សាលាឧទ្ធរណ៍ពិតជាសំអាងហេតុដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយមែន ។ ហើយឈ្មោះ លី ណារី លើកតែអង្គហេតុ ពុំបានលើកពីអង្គច្បាប់ទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់គូភាគីនិងសេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ៦៣ ចុះថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ១៩៨៨របស់អ្នកស្រី លី ណារី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា : ការដែលតុលាការខេត្តបាត់ដំបង និង សាលាឧទ្ធរណ៍សំរេចប្រគល់

ផ្ទះទំនាស់លេខ ៤៩អឺ១៥ អោយទៅលោក ជូ គឹមរិន ហើយទុកផ្លូវអោយអ្នកស្រី ទេព ណាត ឆ្លងកាត់ដោយសំអាងហេតុថា ពិតជាមានការលក់ ទិញពិតប្រាកដមែននោះ ជាការភ័ន្ត-ច្រឡំពីព្រោះថា ការលក់ទិញនេះ ពុំមានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរទេ ដោយគ្រាន់តែដើមចោទអះអាងថា ទិញផ្ទះនេះក្នុងតម្លៃ ២ជី ៥ហ៊ុន ហើយចុងចម្លើយអះអាងថាមាស ២ជី ៥ហ៊ុន នេះជាថ្លៃលក់ផ្លូវឡើងចុះឆ្លងកាត់ទៅផ្ទះដើមចោទប៉ុណ្ណោះ ដូច្នេះតាមមាត្រា ២៣ នៃក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ចុះថ្ងៃទី ២៨.១០.៨៧ ការលក់ទិញនេះត្រូវបានបកស្រាយជាប្រយោជន៍ដល់ចុងចម្លើយ ។

- យល់ឃើញថា : អ្នកស្រី លី ណារី និង អ្នកស្រី ទេព ណាត បានកាន់កាប់ និង រស់នៅលើផ្ទះទំនាស់នេះជាប់ជាអចិន្ត្រៃយ៍ ហើយបានរដ្ឋអំណាចទទួលស្គាល់ផងដែរ ម្យ៉ាងទៀតក្រោយពេលប្រគល់ទទួលមាសរួចហើយ ក៏ចុងចម្លើយ និង តពីយជននៅតែប្រើប្រាស់ផ្ទះទំនាស់នេះជាបន្តមកទៀតពុំដែលបានផ្ទេរបង់ចោលឡើយ ដូច្នេះអ្នកស្រីមានសិទ្ធិលើផ្ទះទំនាស់នេះ តាមមាត្រា ២ នៃអនុក្រឹត្យលេខ ២៥ អ.ន.ក្រ ចុះថ្ងៃទី ២២.៤.៨៩ ។

- យល់ឃើញថា : តួភាគីនៃរឿងក្តីនេះបានផ្ញើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំ-ជំរះរឿងនេះកំបាំងមុខតួភាគី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា : កាលដែលមេធាវីដើមចោទលើកឡើងថា ពិតជាមានការលក់ទិញផ្ទះរវាងអ្នកស្រី ទេព ណាត និង លោក ជូ គឹមរិន ដោយលើកសំអាងដែលជាសាក្សីរបស់ដើមចោទនោះ តុលាការកំពូលពុំអាចពិចារណាបានឡើយ ម្យ៉ាងទៀតក្រោយពីការប្រគល់ប្រាក់ថ្លៃផ្ទះរួចហើយ ចុងចម្លើយនៅតែប្រើប្រាស់ និង កាន់កាប់បន្តទៀតនោះបញ្ជាក់ថា ការប្រគល់ និង ទទួលប្រាក់នេះពុំប្រាកដថាជាការលក់ផ្តាច់ផ្ទះទាំងមូលឡើយ ។

- យល់ឃើញថា : សាលដីកាឧទ្ធរណ៍លេខ ១០១ ចុះថ្ងៃទី ១៦ ខែមិនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី កំបាំងមុខ

តួភាគី ប៉ុន្តែចាត់ទុក ជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ៦៣ ចុះថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ១៩៩៨ របស់ អ្នកស្រី-លី ណារី ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីកាឧទ្ធរណ៍លេខ ១០១ ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងឧទ្ធរណ៍លេខ ១៦៣ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៨



៧

របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ១៩.០០០រៀល ដែលអ្នកស្រី ទេព ណាត បានបង់រួច ហើយនឹ :

- ពន្ធចុះបញ្ជីក្ដី និង ពន្ធថ្លឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន-៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីការកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតម្រូវអោយលោក ជូ គឹមរិន សងប្រាក់ចំនួន ១៩.០០០រៀល នេះទៅអ្នកស្រី - ទេព ណាត វិញ ។

៥- សាលដីកានេះជំនុំជំរះនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩៩ និង ប្រកាសជា សាធារណៈ នៅថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ ។